ព្រឹត្តិបត្រព័ត៌មាន គ.ជ.ប
NEC BULLETIN
គ.ជ.ប

លេខ ០២ ចេញផ្សាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩

ឆ្នាំ២០១៩នេះ គ.ជ.ប ត្រូវអនុវត្តភារកិច្ចសំខាន់ៗចំនួន ៣ ព្រមគ្នា

ក្នុងឆ្នាំ២០១៩នេះ យោងតាមច្បាប់បោះឆ្នោត និងតាមការចាំបាច់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវអនុវត្តភារកិច្ចសំខាន់ៗចំនួន ៣ ព្រមគ្នា នេះបើតាមប្រសាសន៍ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប នៅក្នុងពិធី

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប

បិទវគ្គបណ្តុះបណ្តាល ស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ ការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក

មាតិកា

ទំព័រ

- ឆ្នាំ២០១៩នេះ គ.ជ.ប ត្រូវអនុវត្តភារកិច្ចសំខាន់ៗ..... ១
- គ.ជ.ប បើកវគ្គបណ្តុះបណ្តាលទាក់ទងនឹងការងារ.....៣
- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៤
- សេចក្តីជូនដំណឹងលេខ ០០២ .....៧
- បណ្ណាល័យរូបភាព៖ សកម្មភាពបណ្តុះបណ្តាល.....៨
- សេចក្តីជូនដំណឹងលេខ ០០៥ .....១០
- គ.ជ.ប បានសម្រេចជាផ្លូវការលើ បទបញ្ជា និងនីតិវិធី.....១១
- គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ១២
- គណៈកម្មការរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង ១៣
- ការងារសំខាន់ៗរបស់ គ.ជ.ប ទាក់ទងនឹង ១៤

តទៅទំព័រទី ២

តមកពីទំព័រទី ១ ឆ្នាំ២០១៩នេះ...

ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ នាព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩។ ឯកឧត្តមបានមានប្រសាសន៍ថា ការងារសំខាន់ៗទាំង ៣ នោះ រួមមាន ៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣
- ការប្រឡងប្រជែងជ្រើសរើសសមាជិកលេខាធិការដ្ឋាន នៃរាជធានី ខេត្ត។

ការងារទាំង ៣ ខាងលើនេះត្រូវបាន គ.ជ.ប ត្រៀមទាំងក្របខណ្ឌច្បាប់ និងផែនការដែលត្រូវធ្វើព្រមគ្នាតាំងពីចុងឆ្នាំ២០១៨។ ការងារនេះចាប់ផ្តើមពីខែកុម្ភៈ ហើយត្រូវបញ្ចប់

តំណាងតាគីពាក់ព័ន្ធចូលរួមក្នុងវគ្គបណ្តុះបណ្តាល

ជាបន្តបន្ទាប់ទៅតាមប្រតិទិនកំណត់។

នៅក្នុងពិធីបិទវគ្គបណ្តុះបណ្តាលនោះដែរ ឯកឧត្តមក៏បានណែនាំដល់សិក្ខាកាមដូចតទៅ ៖

- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ជាការបោះឆ្នោតអសកល ហើយអ្នកបោះឆ្នោត គឺជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង។ សម្រាប់ការចុះ(ស្រង់)ឈ្មោះបោះឆ្នោតពុំមានការលំបាកទេ តែត្រូវយកចិត្តទុកដាក់ក្នុងការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោត ឱ្យបានត្រឹមត្រូវ រាងបញ្ជីបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ ដែលត្រូវប្រើសម្រាប់បោះឆ្នោត

ឯកឧត្តម ងេត នីថា អគ្គលេខាធិការ គ.ជ.ប ជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាល

និងសំខាន់ទៀតក្នុងករណីមានការផ្លាស់ប្តូរសមាជិក កបយ.ស ព្រោះពេលវេលាមានកំណត់។

- ត្រូវរៀបចំផែនការប្រតិទិនឱ្យបានត្រឹមត្រូវទាន់ពេលវេលា និងមានប្រសិទ្ធភាពសម្រាប់ការបណ្តុះបណ្តាលបន្តក្នុងរាជធានី ខេត្ត។
- ត្រូវកំណត់ការកិច្ចច្បាស់លាស់រវាង គធ.ខប លគធ.ខប និង លធ.ខប
- ត្រូវពង្រឹងកិច្ចសហការតាមតួនាទីជាមួយភាគីពាក់ព័ន្ធ ជាពិសេសជាមួយអាជ្ញាធរមានសមត្ថកិច្ចលើសៀគាំទ្រ និងការងារសន្តិសុខ។

សូមបញ្ជាក់ថា សិក្ខាកាមចូលរួមក្នុងវគ្គបណ្តុះបណ្តាលខាងលើសរុបមាន ចំនួន ១៣២នាក់ ក្នុងនោះស្ត្រី ១៧នាក់ រួមមាន ៖

- មន្ត្រីបោះឆ្នោតមកពី ២៥ រាជធានី ខេត្ត ចំនួន ៩៨នាក់ ស្ត្រី ១០នាក់។
- តំណាងគណបក្សនយោបាយ ចំនួន ១៥នាក់ មកពី

តំណាងតាគីពាក់ព័ន្ធចូលរួមក្នុងវគ្គបណ្តុះបណ្តាល

គណបក្ស ចំនួន ១២ គឺគណបក្សប្រជាជនកម្ពុជា ខ្មែររួបរួមជាតិ សញ្ជាតិកម្ពុជា សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ប្រជាធិបតេយ្យមូលដ្ឋាន សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ យុវជនកម្ពុជា ធម្មាធិបតេយ្យ ឆន្ទៈខ្មែរ មាតុភូមិយើង ខ្មែរតែមួយ និងគណបក្សនគរប្រជាធិបតេយ្យ។

- តំណាងក្រសួងមហាផ្ទៃ ចំនួន ៣នាក់។
- តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៦នាក់ ស្ត្រី ៧នាក់ មកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៦ គឺសមាគមស្ត្រីសម្រាប់អភិវឌ្ឍន៍សិទ្ធិមនុស្ស ឧស្សាហកម្មកសិកម្ម អង្គការសេវាប្រជាធិបតេយ្យ អង្គការសុខភាពផ្លូវចិត្តបែបបុរាណ និងសម័យ សមាគមអរុណរះ សមាគមជ័យលាភីបញ្ញាជនកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា U.Y.F.C អង្គការសម្ព័ន្ធស្ត្រីខ្មែរការពារសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍អង្គការ NICFEC សមាគម កូ កឺ អេ សមាគមអ្នកលក់ឱសថកម្ពុជា សមាគមសហគមន៍ទេសចរណ៍ សមាគមយុវជនសេដ្ឋកិច្ចរាជធានីភ្នំពេញ សមាគមសម្ព័ន្ធយុវជនមូស្លីមកម្ពុជា អង្គការសហគមន៍គ្រួសារអភិវឌ្ឍន៍កសិកម្ម សមាគមនារី ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ និងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា៕

គ.ជ.ប បើកវគ្គបណ្តុះបណ្តាលទាក់ទងនឹងការងារសំខាន់ៗចំនួន ២

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបើកវគ្គបណ្តុះបណ្តាលការងារសំខាន់ចំនួន ២ ក្នុងពេលតែមួយ គឺការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន សម្រាប់ការចុះ

ឯកឧត្តម ម៉ុក ដាវ៉ា អគ្គលេខាធិការរង គ.ជ.ប

ឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣។

ការបើកវគ្គនេះបានប្រព្រឹត្តទៅក្រោមអធិបតី ឯកឧត្តម **ម៉ុក ដាវ៉ា** អគ្គលេខាធិការរង គ.ជ.ប នាថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយមានសិក្ខាកាមចូលរួមសរុប ចំនួន ១៣២នាក់ ដែល

មន្ត្រី លធ.ខប ចូលរួមក្នុងវគ្គបណ្តុះបណ្តាល

ជាមន្ត្រីលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត មន្ត្រីគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត តំណាងគណបក្សនយោបាយ ចំនួន ១២ និងសមាគម អង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៤ តំណាងក្រសួងមហាផ្ទៃ និងក្រសួងព័ត៌មាន។

ឯកឧត្តម **ម៉ុក ជាវ៉ា** បានលើកឡើងថា គ្រូបង្គោល គ.ជ.ប ត្រូវធ្វើការបណ្តុះបណ្តាលលើប្រធានបទចំនួន ៦ រយៈពេល ២ថ្ងៃ (ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩) រួមមាន៖

១. សេចក្តីណែនាំស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន

តំណាងតាគីពាក់ព័ន្ធចូលរួមក្នុងវគ្គបណ្តុះបណ្តាល

២. ផែនការណែនាំស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន ការិយាល័យចុះឈ្មោះបោះឆ្នោត និងការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការចុះឈ្មោះបោះឆ្នោត

៣. នីតិវិធីនៃការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការបញ្ជូនបញ្ជីឈ្មោះមក គ.ជ.ប ការរៀបចំ ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង

ឯកឧត្តម ម៉ុក ជាវ៉ា អគ្គលេខាធិការរង គ.ជ.ប ជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាល

៤. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

៥. ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ និងការដោះស្រាយពាក្យបណ្តឹង

៦. ការណែនាំអំពីការផ្សព្វផ្សាយបន្តនៅរាជធានី ខេត្ត ស្តីពីការចុះឈ្មោះបោះឆ្នោត។

សូមជម្រាបជូនថា ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅតាមឃុំ សង្កាត់ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩៕

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់អាណត្តិទី៣ មានការកើនឡើងចំនួន ៧៩០ រូប

ចំនួនសមាជិកក្រុមប្រឹក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ខាងមុខនេះ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត មានចំនួន ៥៥៩ រូប កើនឡើង ១៦៦ រូប ក្រុមប្រឹក្សាស្រុក ខណ្ឌ មានចំនួន ៣,៥៥៥ រូប កើនឡើង ៦២៤ រូប និងការិយាល័យបោះឆ្នោតមាន ចំនួន ២០៣ ការិយាល័យ។ ខាងក្រោមនេះ ជាសេចក្តីប្រកាសព័ត៌មាន លេខ ០០១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: 009 គ.ជ.ប.ប្រ.ក

សេចក្តីប្រកាស
ស្តីពី
ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្នុងព្រះរាជាណាចក្រកម្ពុជា
សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩

- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងអនុក្រឹត្យលេខ ២២អនក្រ.បក ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមប្រកាសផ្សព្វផ្សាយជូនជាសាធារណៈថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩ ខាងមុខនេះ ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់តាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗចំណុះរាជធានី ខេត្តពាក់ព័ន្ធ ដូចខាងក្រោម៖

ល.ក	ឈ្មោះរាជធានី ខេត្ត	ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត	ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ	ចំនួនក្រុង ស្រុក ខណ្ឌ	ផ្សេងៗ
01	បន្ទាយមានជ័យ	25	169	9	

02	បាត់ដំបង	27	260	14	
03	កំពង់ចាម	27	204	10	
04	កំពង់ឆ្នាំង	23	140	8	
05	កំពង់ស្ពឺ	25	154	8	
06	កំពង់ធំ	25	169	9	
07	កំពត	25	148	8	
08	កណ្តាល	27	221	11	
09	កោះកុង	19	87	7	
10	ក្រចេះ	21	108	6	
11	មណ្ឌលគិរី	15	59	5	
12	ភ្នំពេញ	27	270	14	
13	ព្រះវិហារ	19	112	8	
14	ព្រៃវែង	27	249	13	
15	ពោធិ៍សាត់	21	121	7	
16	រតនគិរី	19	115	9	
17	សៀមរាប	27	216	12	
18	ព្រះសីហនុ	19	71	5	
19	ស្ទឹងត្រែង	17	80	6	
20	ស្វាយរៀង	23	140	8	
21	តាកែវ	27	192	10	
22	កែប	15	26	2	
23	ប៉ៃលិន	15	30	2	
24	ឧត្តរមានជ័យ	19	77	5	
25	ត្បូងឃ្មុំ	25	137	7	
សរុបទូទាំងប្រទេស		**559**	**3,555**	**203**	

ថ្ងៃចន្ទ ៧រោក ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ស៊ិក ប៊ុនហុក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០០២ គ.ជ.ប. ស.ន.៣

សេចក្តីជូនដំណឹង
ស្តីពី
ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣ **គណៈកម្មាធិការជាតរៀបចំការបោះឆ្នោត (គ.ជ.ប)** សូមជូនដំណឹងជាសាធារណៈដល់ស្ថាប័នពាក់ព័ន្ធ គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសជ្រាបថា ៖

- ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ និងសមាជិកក្រុមប្រឹក្សាខេត្តនីមួយៗ សម្រាប់អាណត្តិទី៣ ត្រូវបានកំណត់ចំនួនប្រាំរយហាសិបប្រាំបួន (៥៥៩) នាក់។
- ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣ ត្រូវបានកំណត់ចំនួនបីពាន់ប្រាំរយហាសិបប្រាំ (៣,៥៥៥) នាក់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័នពាក់ព័ន្ធ គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេសជ្រាបជាព័ត៌មាន។

ថ្ងៃពុន ១០រោចខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៩

ជ.គណៈកម្មាធិការជាតរៀបចំការបោះឆ្នោត
ប្រធាន

សុិក ប៊ុនហុក

បណ្ណាល័យរូបភាពៈសកម្មភាពបណ្តុះបណ្តាលស្តីពីការស្រង់
ឆ្នាំ២០១៩ ការចុះឈ្មោះបោះឆ្នោត និងការចុះបញ្ជីគ
បោះឆ្នោតជ្រើសរើសក្រុមប្រ

រូបភាពសកម្មភាពវគ្គបណ្តុះបណ្តាលរបស់ គ.ខ.ប ពោធិ៍សាត់ ស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ ការចុះឈ្មោះបោះឆ្នោត និងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ កាលពីថ្ងៃសៅរ៍ ទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មានដែលការចុះឈ្មោះបោះឆ្នោត ណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ការ ប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩

រូបតាពសកម្មតាពវគ្គបណ្តុះបណ្តាលរបស់ គ.ខ.ប ក្រចេះ ស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន និងការចុះឈ្មោះ បោះឆ្នោត ឆ្នាំ២០១៩ ការចុះឈ្មោះបោះឆ្នោត និងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ កាលពីថ្ងៃសៅរ៍ ទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០០៤ គ.ជ.ប.ន.ជ.ណ

សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជូនដំណឹងដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ឱ្យបានជ្រាបថា ការយកព័ត៌មានអំពីដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អ្នកសារព័ត៌មានទាំងអស់ត្រូវមានបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានដែលចេញដោយ គ.ជ.ប ។

ដើម្បីទទួលបានបណ្ណសម្គាល់ខ្លួន អ្នកសារព័ត៌មានត្រូវដាក់ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មាន ដែលផ្តល់ជូនដោយឥតគិតថ្លៃពី គ.ជ.ប ។

ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- លិខិតបញ្ជាក់ ឬលិខិតស្នើសុំធ្វើបណ្ណអ្នកសារព័ត៌មាន គ.ជ.ប ពីសាមីអង្គភាព
- ច្បាប់ចម្លងនៃបណ្ណអ្នកសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេបមានបិទរូបថត និងរូបថត ៤x៦ ចំនួន ១សន្លឹកទៀតសម្រាប់ធ្វើបណ្ណ
- ច្បាប់ចម្លងនៃលិខិតឆ្លងដែន (សម្រាប់ជនបរទេស) ។

ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានអន្តរជាតិ ដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងនៃលិខិតឆ្លងដែន
- បណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេបមានបិទរូបថត និងរូបថត ៤x៦ ចំនួន ១សន្លឹកទៀតសម្រាប់ធ្វើបណ្ណ ។

ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានឯករាជ្យ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងនៃបណ្ណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមអ្នកសារព័ត៌មាន
- ប្រវត្តិរូបសង្ខេបមានបិទរូបថត និងរូបថត ៤x៦ ចំនួន ១សន្លឹកទៀតសម្រាប់ធ្វើបណ្ណ
- អត្ថបទចុងក្រោយ ដែលបានសរសេរចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់អំឡុងឆ្នាំចុងក្រោយ ចំនួន ៣ អត្ថបទ ។

ពាក្យសុំ និងបែបបទសម្រាប់សុំបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មាន មានផ្តល់ជូននៅទីស្តីការ គ.ជ.ប (ជាន់ទី៨ បន្ទប់B) និងអាចទាញយកពីគេហទំព័រ គ.ជ.ប https://www.necelect.org.kh/khmer/content/form-3662 ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ ទាំងអស់ជ្រាបជាព័ត៌មាន ៕

ថ្ងៃពុធ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៩
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

សុឹក ប៊ុនហុក

គ.ជ.ប បានសម្រេចជាផ្លូវការលើ បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប

កាលពីព្រឹកថ្ងៃសុក្រ ទី២២ ខែកុម្ភៈ ឆ្នាំ២០១៩នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចជាផ្លូវការលើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩។

សេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះ មាន ៣ជំពូក ១៣ផ្នែក និងឧបសម្ព័ន្ធ ចំនួន ៧ ស្មើនឹង ៣២៥ទំព័រ ហើយបានបញ្ជូនទៅឱ្យភាគីពាក់ព័ន្ធ ផ្តល់អនុសាសន៍ កាលពីថ្ងៃ១៥ ខែមករា ឆ្នាំ២០១៩។

តាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់

បន្ទាប់ពីទទួលបានអនុសាសន៍ពីស្ថាប័ន ចំនួន ១០ ពាក់ព័ន្ធនឹងសេចក្តីព្រាងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើអនុសាសន៍ទាំងនោះ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ នាទីស្តីការ គ.ជ.ប ដែលមានការចូលរួមពីតំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តំណាងក្រសួង ស្ថាប័នរដ្ឋ ចំនួន ៥ គណបក្សនយោបាយ ចំនួន ៤ អង្គការមិនមែនរដ្ឋាភិបាល ចំនួន ២ អង្គភាពសារព័ត៌មាន ចំនួន ៨ រួមទាំងមន្ត្រី គ.ជ.ប លធ.ខប ចំនួន ៣១នាក់ សរុបអ្នកចូលរួម ចំនួន ៦៣នាក់។

តាមប្រសាសន៍របស់ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩ ផ្លូវការនេះ នឹងត្រូវបានបង្ហោះនៅលើគេហទំព័រ (Website) គ.ជ.ប www.necelect.org.kh ក្នុងពេលឆាប់ៗនេះ ៕

តាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់

គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ប្រជុំរៀបចំផែនការការងារ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩

ការគោរពតាមគោលការណ៍ណែនាំជាដំណាក់កាលទៅតាមប្រតិទិនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ គឺជាភារកិច្ចដែលគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ត្រូវធ្វើនៅពេលបច្ចុប្បន្ន "នេះជាការអះអាងរបស់លោក **មាង ម៉ែងហ៊ួន** ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ក្នុងកិច្ចប្រជុំស្តីពីការអនុវត្តតាមប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ នៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៩"។

លោក មាង ម៉ែងហ៊ួន ប្រធាន គ.ខ.ប កំពង់ចាម

លោក **មាង ម៉ែងហ៊ួន** ក៏បានណែនាំឱ្យមន្ត្រីនៃគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម ទាំងអស់ប្រកាន់ភ្ជាប់ជំហរជាអ្នកបម្រើសេវាជូនភាគីពាក់ព័ន្ធការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតខាងមុខនេះ ប្រព្រឹត្តទៅដោយរលូន។ លោកបានបន្ថែមថា យោងតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ខេត្តកំពង់ចាមមានសមាជិកក្រុមប្រឹក្សាសរុប ចំនួន ២៣១រូប ក្នុងនោះ ២៧រូបជាសមាជិកក្រុមប្រឹក្សាខេត្ត និង ២០៤ ជាសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក។

យោងតាមប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះនៅ គឧ.ខប នឹងចាប់ផ្តើមពីថ្ងៃទី០៧ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ហើយការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលនៅតាមការិយាល័យបោះឆ្នោត នឹងចាប់ផ្តើមពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩។

លោកស្រី **យឹម សុធានី** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត បានណែនាំឱ្យមន្ត្រីត្រៀមឯកសារផ្សព្វផ្សាយអំពីការដាក់ពាក្យសុំចុះភ្នាក់ងារគណបក្សនយោបាយសម្រាប់ការចុះឈ្មោះបោះឆ្នោត ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតមុនពេលចុះឈ្មោះបោះឆ្នោត។ លោកស្រីបាន

តាគីពាក់ព័ន្ធចូលរួមកិច្ចប្រជុំ ក្នុង គ.ខ.ប កំពង់ចាម

បន្ថែមថា គណៈកម្មការរៀបចំការបោះឆ្នោតខេត្តនឹងធ្វើការប្រជុំជាមួយភាគីពាក់ព័ន្ធជាបន្តបន្ទាប់ ដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

សូមបញ្ជាក់ថា កិច្ចប្រជុំនេះ មានការចូលរួមដោយ ៖ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកំពង់ចាម អនុប្រធាន សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល សមាជិកទទួលបន្ទុកផ្នែកគណនេយ្យ និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលបម្រើការងារនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម សរុបចំនួន ១១ នាក់៕

គណៈកម្មការរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង ប្រជុំរៀបចំផែនការការងារ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩

ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង បានណែនាំដល់មន្ត្រីក្រោមឱវាទត្រូវសិក្សាស្រាវជ្រាវ និងប្រើប្រាស់ចំណេះដឹង បទពិសោធន៍ដែលមានស្រាប់ចូលរួមអនុវត្តការងារ

លោក ពុយ ចាន់ថាឡាក់ ប្រធាន គ.ខ.ប ស្ទឹងត្រែង

បោះឆ្នោតឱ្យបានជោគជ័យ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩។ ការណែនាំនេះត្រូវបានធ្វើឡើងក្នុងកិច្ចប្រជុំ ស្តីពីការរៀបចំកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩ នៅសាលប្រជុំលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩។

លោក **ពុយ ចាន់ថាឡាក់** ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង ក៏បានសំណេះសំណាល ជាមួយសមាជិក សមាជិកា គ.ខ.ប ទាក់ទងទៅនឹងការងារសំខាន់ៗមួយចំនួន ដូចជា ៖

- ការតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី
- ការសុំច្បាប់នៅក្រៅក្របខ័ណ្ឌដើម្បីបម្រើការងារបោះឆ្នោត
- ការគោរពបទបញ្ជាផ្ទៃក្នុង
- ការអនុវត្តការងារតាមប្រតិទិនរបស់ គ.ជ.ប និងឈានទៅបន្តការងារចុះឈ្មោះបោះឆ្នោត

បន្ទាប់ពីការណែនាំរបស់លោកប្រធាន គ.ខ.ប លោក **ហង់ កុង** ប្រធានលេខាធិការដ្ឋានខេត្ត រៀបចំការបោះឆ្នោតខេត្តស្ទឹងត្រែង បានបញ្ជាក់អំពីការដាក់ពាក្យសុំនៅក្រៅក្របខ័ណ្ឌដើមរបស់មន្ត្រីរាជការ ដែលបានចូលមកបម្រើការងារបោះឆ្នោតជាមន្ត្រីកិច្ចសន្យា ហើយក៏បានរំលឹកដល់មន្ត្រីក្របខ័ណ្ឌ និង

សកម្មភាពប្រជុំ ក្នុង គ.ខ.ប ស្ទឹងត្រែង

មន្ត្រីកិច្ចសន្យាទាំងអស់ត្រូវគោរពឱ្យបាននូវបទបញ្ជាផ្ទៃក្នុងនៃស្ថាប័នមួយនេះ។

មុននឹងបញ្ចប់កិច្ចប្រជុំលោក **ពុយ ចាន់ថាឡាក់** បានជម្រាបអង្គប្រជុំថា ក្នុងដំណើរការនៃការបោះឆ្នោត ឆ្នាំ២០១៩ ចំពោះមុខនេះ ផ្នែកប្រតិបត្តិការ និងផ្នែកសេវាកម្មច្បាប់ត្រូវត្រៀមសម្របសម្រួលការងារស្រង់ឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងត្រៀមទទួលនូវការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។ បន្ទាប់ពីការបណ្តុះបណ្តាលរួច គ.ខ.ប នឹងរៀបចំការប្រជុំផ្សព្វផ្សាយជាមួយតំណាងគណបក្សនយោបាយ គណៈបញ្ជាការសន្តិសុខខេត្ត និងអាជ្ញាធរពាក់ព័ន្ធឱ្យបានទូលំទូលាយ។

សូមបញ្ជាក់ថា កិច្ចប្រជុំនេះ មានការចូលរួមដោយ ៖ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តស្ទឹងត្រែង អនុប្រធាន សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល សមាជិកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលបម្រើការងារនៅ គ.ខ.ប ស្ទឹងត្រែង សរុប ចំនួន ១១ នាក់៕

ការងារសំខាន់ៗរបស់ គ.ជ.ប ទាក់ទងនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ពីថ្ងៃទី០៥ ដល់ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩

ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩ គ.ជ.ប បាន៖

- ចេញសេចក្តីណែនាំ ស្តីពីការចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣ ឆ្នាំ២០១៩។
- ចេញលិខិតជូនឯកឧត្តម**ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីវឌ្ឍនភាពលើការអនុវត្តគម្រោង និងសកម្មភាពនានាក្នុងក្របខណ្ឌទំនាក់ទំនងរវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកម្ពុជា និងសហភាពអឺរ៉ុប។

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ គ.ជ.ប បាន៖

- ចេញសេចក្តីជូនដំណឹង ដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ជ្រាបថា ការយកព័ត៌មានអំពីដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩ អ្នកសារព័ត៌មានទាំងអស់ត្រូវមានបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានដែលចេញដោយ គ.ជ.ប ។

ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ គ.ជ.ប បាន៖

- ចេញលិខិតអញ្ជើញ លោកប្រធានគណៈកម្មការរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តមណ្ឌលគីរី តំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តំណាងក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ ក្រសួងការពារជាតិ តំណាងគណបក្សប្រជាជន គណបក្សយុវជនកម្ពុជា គណបក្សមាតុភូមិយើង តំណាងសមាគមជ័យលាភីបញ្ញាជនកម្ពុជា (V.I.S.A) និងតំណាងសហគមន៍គ្រួសារអភិវឌ្ឍន៍កសិកម្ម (FADC) ដើម្បីចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធី សម្រាប់

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី៣ នៅសាលសន្និសីទ សារព័ត៌មាន អគារថ្មី គ.ជ.ប ។

- ចេញលិខិតជូន ឯកឧត្តម **ឆុច សុន** សមាជិក គ.ជ.ប ដើម្បីចូលរួមសន្និបាតត្រួតពិនិត្យការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ដែលប្រព្រឹត្តទៅរយៈពេល ២ថ្ងៃ នៅថ្ងៃពុធ ទី១៣ និងថ្ងៃព្រហស្បតិ៍ ទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ ចាប់ពីវេលាម៉ោង ៧:៣០នាទីព្រឹក នៅសាលប្រជុំអគារ "S" ទីស្តីការក្រសួងមហាផ្ទៃ ។
- ចេញលិខិតបង្គាប់ការ អ្នករាជការ គ.ជ.ប ចំនួន ១៦រូប ជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល និងជំនួយការវគ្គបណ្តុះបណ្តាល សម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩ នៅថ្ងៃទី១៨-១៩ ខែកុម្ភៈ ឆ្នាំ២០១៩ នៅ គ.ជ.ប ។
- ចេញលិខិតអញ្ជើញ លោក លោកស្រី ប្រធានគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩ នៅសាលសន្និសីទ គ.ជ.ប (ជាន់ទី១) នាថ្ងៃទី១៨-១៩ ខែកុម្ភៈ ឆ្នាំ២០១៩ ។

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ គ.ជ.ប បាន៖

- ចេញលិខិតអញ្ជើញ ឯកឧត្តមទីប្រឹក្សា គ.ជ.ប និងជាប្រធាននាយកដ្ឋានគ្រប់នាយកដ្ឋាន និងឯកឧត្តមទីប្រឹក្សា គ.ជ.ប និងជាប្រធានលេខាធិការដ្ឋាន ដើម្បីចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី៣ ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប នៅសាលសន្និសីទ គ.ជ.ប (ជាន់ទី១)។
- ចេញសេចក្តីជូនដំណឹង ស្តីពីការផ្ទេរសិទ្ធិរបស់ប្រធានគណបក្សនយោបាយ ជូនតំណាងដើម្បីចុះហត្ថលេខាលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ និងពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ដើម្បីសង្កេតមើលការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩។

ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩ គ.ជ.ប បាន៖

- ចេញលិខិតអញ្ជើញ ឯកឧត្តមអគ្គលេខាធិការរង គ.ជ.ប ឯកឧត្តមទីប្រឹក្សា គ.ជ.ប និងជាប្រធាននាយកដ្ឋានគ្រប់នាយកដ្ឋាន និងឯកឧត្តមទីប្រឹក្សា គ.ជ.ប និងជាប្រធានលេខាធិការដ្ឋាន ដើម្បីចូលរួមបិទវគ្គបណ្តុះបណ្តាល ស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប នៅសាលសន្និសីទ គ.ជ.ប (ជាន់ទី១)៕

រូបភាពសកម្មភាព ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ ការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្ស នយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩

ឯកឯកាន គ.ជ.ប រិចីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ
ទូរស័ព្ទ (Tel) : (+855) 12 855 018
អ៊ីម៉ែល (Email): necinfo@forum.org.kh

រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត